# អំណាច ជា អ្វី ?




អំណាច ជា អ្វី ?


Général Ith Soun et moi

អំណាចមិនមែន ជាវត្ថុ ដែលគេអាច បែងចែក ជាប្រភេទ បែបនេះ បែបនោះបាននោះឡើយ ឬ អ្នកនេះមាន ឬ អ្នក នោះឥតមាន នោះទេ។ តែគំនិតទុក អំណាច ជាវត្ថុនេះ ត្រូវគេ យកមកប្រើ ក្នុងនីតិសាធារណៈ ដើម្បី បែងចែក រវាង អំណាច រដ្ឋ នឹង វិស័យស៊ីវិល និង ឯកជន ឬ ក្នុង ភាសានយោបាយ នៃ ទេសធម៌ ដូចគេ ប្រើពាក្យ សំរាប់បែងចែក អំណាចនីតិ បញ្ញត្តិ, នីតិប្រតិបត្តិ និង តុលាការ។

យើងដឹងថា អ្នកប្រាជ្ញសង្គមទួទៅ ត្រូវគ្នា នាំគ្នា ច្រានចោល នូវ គំនិត ប្រើពាក្យប្រៀបធៀប និង សារជាតិនិយម នៃ ពាក្យអំណាច។ ឧទាហរណ៍ ដូចគេ ទម្លាប់និយាយថា អំណាច ទឹកប្រាក់ ឬ អំណាចវិទ្យាសាស្ត្រ ជាជាង និយាយឲចំថា អំណាច សេដ្ឋី ឬ អំណាច អ្នកប្រាជ្ញវិទ្យាសាស្ត្រ។ ម្យ៉ាងទៀត អ្វីជាសារ ជាតិនិយម នៃ ពាក្យអំណាច ដោយឥតយកវា មកនិយាយ ក្នុង ប្រព័ន្ធ នៃ ការទាក់ទងគ្នា ទៅវិញទៅមក និង បរិការណ៍

## អំណាច ជា អ្វី ?

នៃ ប្រវត្តិសាស្ត្រ ដែល ជា ប្រវត្តិការណ៍ របស់ អត្ថន័យ នៃ ពាក្យ ដែលលើយកមក និយាយ ខាងលើនេះ។

ពិតមែនតែយើងអាចដឹងថា ប្រាក់ វាមាន អំណាច ទៅលើផ្សារសេដ្ឋកិច្ច តែវាគ្មាន ឥតទិ្ធពល អ្វីទាំងអស់ទៅលើ សមរភូមិ នៃ វិទ្យាសាស្ត្រ ឬ ក្នុង សង្គម យុកដំបូង ព្រោះយើងដឹងថា មិនមែនប្រាក់ទេ ជាអ្នកបង្កើត ការចេះដឹង ហើយ ក្នុង សង្គម យុកដំបូង ភោគទ្រព មិនមែនជា ប្រភព នៃ អំណាច នោះទេ។ អំណាច មានប្រភព ក្នុងជំនឿ ដូច សង្គមវិទូ បារាំង ឈ្មោះ ក្លូត-លេវី ស្ត្រូស និយាយថា ជំនឿ លើមេធ្មប់ ជា ប្រភព នៃ អំណាចមួយ។ ក្នុងទស្សនៈ សង្គមវិទូនេះ គឺ ចង់បង្ហាញ ថា អំណាច មិនមែន ជាវត្ថុនោះទេ វាជា ការទាក់ទង នៃសង្គម, ជា ពិសេស ជាទំនាក់ទំនងទល់មុខគ្នា រវាង បុគ្គលនឹងបុគ្គល។

ទីនេះ យើងមិនយក ទស្សនៈអំណាច ការទាក់ទង នៃ សង្គម មកសិក្សា ក្នុងជំរៅនោះទេ យើង គ្រាន់តែ លើកផ្នែកមួយ នៃ អំណាច មកជូន ជាមតិ សំរាប់ អ្នកអាន យកវា ទៅពិចារណា។ ប្រធាន ដែលយើង លើកយកមក អធិប្បាយ ទីនេះ គឺ **អំណាច និង អាជ្ញា**។

យើងដឹងថា គ្រប់ ការទំនាក់ទំនង, ការគ្របសង្កត់, ការស្តាប់បង្គាប់ ឬ (អនុភាព) មានជា ធម្មតា នៅក្នុង គ្រប់សង្គម នៃ មនុស្ស និង សង្គម នៃ សត្វ ដែលមាន ឋានានុក្រម។ ក៏បន្តែ

## អំណាច ជា អ្វី ?

យើង សង្កេតឃើញថា នៅក្នុងសង្គម នៃសត្វ វាគ្មាន ការទំនាក់ទំនង ក្នុង សេចក្ដីបញ្ជា ឬ បង្គាប់, ការស្ដាប់ ឱវាទ (ឬអាជ្ញា) រវាង មេនិងកូន។ មេឃ្មុំ, មេស្រមោច, មេកណ្ដៀរ ដែលយើងនឹកស្មានថា ជា មេ បញ្ជា ទៅលើ ឃ្មុំ, ស្រមោច, កណ្ដៀរ ក្នុងសម្បុកនោះ មិនមែនជា បែបបញ្ជា ក្នុងន័យជា ‹មេបញ្ជាការ› ជា អ្នកដឹកនាំ ឬ ជា អ្នកសម្រេចសេចក្ដី ណាមួយនោះឡើយ ទោះបី មេនោះ ជា គោលចាំបាច់ ក្នុងការរស់នៅ ក្នុងសម្បុក ក៏ដោយ។ ការយក សង្គម នៃ សត្វ ខាងលើនេះ មកប្រដូចនឹង សង្គម នៃ មនុស្ស វា គ្មាន យុត្តិការ នោះទេ ព្រោះឃ្មុំ, ស្រមោច, កណ្ដៀរ នីមួយៗ វាមានមុខនាទី របស់វា ទៅតាមសភាវគតិ ឥតចាំបាច់ ទទួលបញ្ជាអ្វីនោះឡើយ ព្រោះជា យន្តការសារីរិក[1] ដែលជា ច្បាប់ធម្មជាតិ នៃ ការរៀបចំ សង្គម របស់បាណសត្វនោះ។ តែបើនិយាយ អំពីពាក្យ ‹បញ្ជា› គឺថា អ្នកទទួល បញ្ជា អាចមាន អំណាច ធ្វើអ្វី ផ្សេងទៀតបាន ក៏ប៉ុន្តែយើងឃើញ អ្នកទទួលបញ្ជា យកសេចក្ដីបង្គាប់នោះ ទៅអនុវត្តយ៉ាងផ្ចិតផ្ចង់ ឥតប្រកែកអ្វីនោះទេ ព្រោះគេជឿ លើ ធម្មានុរូបភាព ឬ ភាពត្រូវច្បាប់ នៃ អំណាច របស់អ្នកបញ្ជា។

ការទំនាក់ទំនង នៃ អាជ្ញានេះ ជា ការបង្កើត របស់មនុស្ស សំរាប់ រកការរៀបរយ នៃ ការរស់នៅក្នុងសង្គម, ជា តក្កកម្ម (ការ

---

[1] យន្តការសារីរិក = Mécanisme physiologique។

## អំណាច ជា អ្វី ?

បង្កើត) មួយ បង្ហាញ ឧត្តមភាព នៃ មនុស្ស ដោយ ប្រៀបធៀប ទៅនឹង សង្គមសត្វ។ ទស្សនវិទូបារាំង ឈ្មោះ អេដងាដ្គ មូរាំង សរសេរថា ការខុសគ្នា រវាង សង្គមមនុស្ស នឹង សង្គមស្វា គឺគេ សង្កេតឃើញថា នៅក្នុង រយៈកាល នៃ ការវិវឌ្ឍន៍ មួយ នៃ សង្គម ទាំងពីរនេះ មនុស្ស ទោះបី នៅរក្សា សត្តភាព ក្នុងការ ទំនាក់ទំនង ជាអនុភាព (ដែលមិនដែលមានជាស្ថាពរ) គឺជា សត្វលោកមួយ ដែល អាចមាន ចំណងនឹងគ្នា ក្នុងការទំនាក់ទំនង ជាអាជ្ញា។ ការទំនងទំនង ជាអាជ្ញានេះ គឺ មនុស្សនាំគ្នា បង្កើតឡើង គ្រប់សណ្ឋាន, គ្រប់កំរិត ក្នុង គោលបំណង រករបៀបរៀបរយ ក្នុងសង្គម និង ជា ទិសភាព ក្នុង សកម្មភាពរួម គឺ ការផ្សុំគ្នា នូវ អំណាចនយោបាយ, អនុភាព នៃសាធារណៈជន និងច្បាប់ ជាអាជ្ញា។

ក្នុងសមាយោគនេះ យើងអាចធ្វើ អនុមាន បានថា មនុស្ស ជាសត្វលោក តែមួយគត់ ដែលអាច ជំទាស់នឹង សណ្ដាប់ធ្នាប់ សង្គមមួយ ដែលគេបាន រៀបចំឡើង។ ដោយហេតុនេះ មនុស្សម្នាក់ៗ មានលទ្ធភាព យល់ព្រម ឬ មិនយល់ព្រម ស្ដាប់បង្គាប់ មនុស្សម្នាក់ទៀត ជាអ្នកបញ្ញា។ លទ្ធភាពនេះ ជា អាការៈ អធិភាព របស់មនុស្ស លើសត្វ ទាំងពួង ជា អាការៈ មានក្នុង ពូជពង្ស នៃ មនុស្ស ដែលជា ច្បាប់ធម្មជាតិ។ តែមាន សង្គមវិទូ មួយចំនួន គេយល់ឃើញថា កំលាំងបាយ, អាវុធ អាចបង្ខំ មនុស្ស ឲស្ដាប់បង្គាប់បាន ដូចនៅ ជំនាន់ ខ្មែរក្រហម៖ ‹ធ្វើ

## អំណាច ជា អ្វី ?

តាមអញឬស្លាប់› ដូច លោក ហ៊ុន សែន (ជាអ្វី?) ក្លាំងពូកែណាស់ គាត់ ប្រើសំដីឡើង សុទ្ធតែ ដាក់ខ្នោះខ្មែរ ឲ តែចូលស្រុក យើង គ្រាន់ចង់ប្រាប់ លោក ហ៊ុន សែន ថា បើ លោកពូកែ លោក មក បរទេស ធ្វើការប្រជុំ ជាសាធារណៈ ជាមួយសហគមន៍ខ្មែរ ធ្វើកាពិភាក្សា តទល់នឹងខ្មែរ ឲសមខ្លួន តាំងអញ ជា អ្នកក្លាហាន។ សហគមន៍ខ្មែរ នៅ បរទេស ធានាគ្រប់បែបយ៉ាង ចំពោះសន្តិសុខ និង សេចក្តីថ្លៃថ្នូរ ក្នុងឋានៈ លោកជា នាយករដ្ឋមន្ត្រី កុំតែក្លាហាន ក្នុង បន្ទាយ អង្គរក្ស របស់លោក។

ឯទៀត ក្នុងសំដីលោក រកចាប់ អ្នកនេះអ្នកនោះ បំពាន លើច្បាប់ បើលោក ក្លាហាន លោក មកនិយាយ ក្នុងវិទ្យុ និង ទូរទស្ស នៅអាមេរិកម្តង ដូចលោក បាននិយាយ ក្នុងបន្ទាយលោក ម្តងលមើល ប្រាកដ ជាសហគមន៍ខ្មែរ គេប្តឹង ឲអាជ្ញាធរចាប់ខ្លួនលោកដាក់ខ្នោះ ដូចលោក និយាយស្រាប់ គឺ ‹មិនពីមុខទេ គឺពីខាងក្រោយខ្នង›។ ជាការជម្មតា លោក មាន អង្គរក្ស ការពារលោក ចំណែក អ្នកប្រឆាំងលោក នៅនាយសមុទ្រ គេមាន ច្បាប់ការពារខ្លួនគេដែរ មិនមែន គេគ្នាន សេចក្តីក្លាហាន ឲលោក បំពានច្បាប់ដាក់ខ្នោះគេនោះទេ។ លោកយកកំលាំងបាយ សម្លុត តែខ្មែរគ្នាឯងទេ តែលោក ខ្លាចយួន កាត់ដីឲយួនស្រួលណាស់ តើ ខ្មែរណាម្នាក់ ដែល មានមនសិការជាតិ អាច នៅជឿលោកថាជា អ្នកស្នេហាជាតិ ?

## អំណាច ជា អ្វី ?

ត្រឡប់ មកអធិប្បាយ អំពី កំលាំង អាចបង្ខំ មនុស្ស ឲស្តាប់បង្គាប់បាន។ ទស្សនៈនេះ មិនពិតជាត្រូវនោះឡើយ ព្រោះថា នៅពេលណា អ្នកណាម្នាក់ ប្រើកំលាំង សម្លុត ឲគេស្តាប់បង្គាប់ខ្លួន ដូចយ៉ាង រហូតទៅដល់ សម្លាប់គេ បើ គេមិនធ្វើតាមខ្លួន ក្នុងលក្ខណៈនេះ គេមិនទុក កំលាំងនោះ ជាអំណាច នោះទេ គេអាច និយាយទៀតថា អ្នកនោះ គ្មានអំណាច ឬ បាត់អំណាច ទៅវិញទេ ព្រោះ ការទំនាក់ទំនង តាមផ្លូវអំណាច គឺត្រូវមាន ការយល់ព្រមទៅវិញទៅមក រវាង អ្នកបញ្ជានឹង អ្នកអនុវត្តិ។ ចំណែក ការប្រើកំលាំង គឺមាន តែ ការបង្ខិតបង្ខំ ពីសំណាក់ អ្នកមានកម្លាំង សំរាប់គោលបំណងខ្លួន តែប៉ុណ្ណោះ។ ក្នុងចំណុចនេះហើយ ដែលគេអាច ឲភាព ខុសគ្នា រវាង កំលាំង និង អំណាច។ ដោយហេតុនេះ យើងអាច បញ្ជាក់ដល់ ប្រជាពលរដ្ឋខ្មែរ អោយបានជ្រាបថា អ្នកដឹកនាំ នៅភ្នំពេញបច្ចុប្បន្ន គ្មានអំណាចអ្វីនោះទេ គឺមានតែ កម្លាំងនិគ្រោះ សំរាប់ ផលប្រយោជន៏គេតែប៉ុណ្ណោះ។ កម្លាំងនេះ គ្មានច្បាប់ ជាអាជ្ញានោះទេ រួមសេចក្តីមក គឺគ្មាន ជម្មានរូបភាព នោះឯង៕